**កម្មវិធីកិច្ចសន្ទនា AVI-SGDs ស្ដីពី «យេនឌ័រ-គោលនយោបាយឆ្លើយតបក្នុងវិស័យព្រៃឈើ - ការចូលរួមរបស់ស្ត្រីក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ»**

**ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥**

**របាយការណ៍សង្ខេប**

## ១-សេចក្ដីផ្ដើម និងទិដ្ឋភាពទូទៅ៖

កម្មវិធីកិច្ចសន្ទនា AVI-SDGs ស្ដីពី **«យេនឌ័រ-គោលនយោបាយឆ្លើយតបក្នុងវិស័យព្រៃឈើ - ការចូលរួមរបស់ស្ត្រីក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ»** ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៨ ខែកញ្ញា ដែលមានសារៈសំខាន់ចំពោះបរិបទនាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃដាក់បញ្ចូលប្រធានបទយេនឌ័រក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលវិបាកនៃការប្រែប្រួលអាកាសធាតុ ដោយមានអ្នកចូលរួមជាស្ត្រីសរុបចំនួន ៥៧% នៃបណ្ដាអ្នកចូលរួមសរុបមកពី ១៨ ស្ថាប័ន។ របាយការណ៍សង្ខេបនេះ ផ្ដោតទៅលើទិដ្ឋភាពទូទៅនៃកិច្ចពិភាក្សា និងខ្លឹមសារសំខាន់ៗរបស់កម្មវិធីកិច្ចសន្ទនាទាំងមូល។ កម្មវិធីកិច្ចសន្ទនានេះត្រូវបានធ្វើឡើងដោយមានសុន្ទរកថា ការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាតុមូលនៅចុងបញ្ចប់ ដែលមានការចូលរួមពីវាគ្មិនកិត្តិយស និងអ្នកតំណាងដ៏ខ្ពង់ខ្ពស់របស់ស្ថានប័នជាតិ និងអន្តរជាតិ ដូចខាងក្រោម៖

១. លោកបណ្ឌិត ងួនផាន ភក្តី អនុប្រធាននៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI)

២. លោកស្រី Melony C. Lindberg ប្រធានអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា (TAF)

៣. លោកស្រី Evangeline Larsen លេខាធិការទី២ នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា

៤. លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគីន អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥. លោកស្រី ធន រដ្ឋា អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គម ក្រសួងកិច្ចការនារី

៦. លោកស្រី ងិន ណារីៈ មន្ត្រីសម្របសម្រួលប្រចាំកម្ពុជា នៃកម្មវិធីជំនួយខ្នាតតូចសម្រាប់មូលនិធិបរិស្ថានសកល នៃកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)

## ២-លទ្ធផល និងខ្លឹមសារសំខាន់ៗ៖

### ២.១. សុន្ទរកថាស្វាគមន៍ដោយ លោកបណ្ឌិត ងួនផាន់ ភក្តី

ចាប់តាំងពីឆ្នាំ ២០១៩ មក វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បានចូលរួមចំណែកដល់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជាតាមរយៈការស្រាវជ្រាវ កិច្ចសន្ទនា និងការលើកកម្ពស់សង្គមមួយប្រកបដោយសន្តិភាព បរិយាប័ន្ន ប្រកបដោយចីរភាព និងសម្របខ្លួន។ ដោយផ្អែកលើបេសកកម្មនេះ AVI បង្កើតបានជាស្នាដៃជាច្រើនគួរឱ្យកត់សម្គាល់រួមមាន៖ អត្ថបទអត្ថាធិប្បាយ អត្ថបទសង្ខេបគោលនយោបាយ អត្ថបទទស្សនៈ សៀវភៅ ទស្សនាវដ្ដី បទសម្ភាសន៍ ការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការស្ទង់មតិ -ល- ។ លទ្ធផលផ្លែផ្កាទាំងនេះត្រូវបានបង្កើតឡើងដោយមានកិច្ចគាំទ្រពីអ្នកជំនាញ ទីប្រឹក្សា អ្នកស្រាវជ្រាវ និស្សិត និងអ្នកហាត់ការជាច្រើនរបស់វិទ្យាស្ថាន។ AVI ក៏ផ្ដោតផងដែរទៅលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែល

ត្រូវបានគេស្គាល់ថាមានលក្ខណៈសកល វិវត្តទៅមុខ បរិយាប័ន្ន ផ្តោតលើមនុស្សជាតិ អភិរក្សជីវៈចម្រុះ និងការពារបរិស្ថាន។ ដោយមើលឃើញថា ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពអាកាសធាតុ ជាពិសេសតួនាទីរបស់ស្ត្រីក្នុងការគ្រប់គ្រង ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការធ្វើផែនការ និងការកៀរគរធនធាន កាន់តែមានសារៈសំខាន់ កម្មវិធីកិច្ចសន្ទនា ដែលទទួលបានការគាំទ្រពីកម្មវិធីពន្លកចំណេះរបស់អង្គការមូលនិធិអាស៊ី និងស្ថានទូតអូស្ត្រាលីប្រចាំទីក្រុងភ្នំពេញ មានគោលបំណង៖ ១) ប្រមូលផ្តុំអ្នកចូលរួមចំណែកដើម្បីធ្វើកិច្ចពិភាក្សា ២) ផ្តល់ព័ត៌មានអំពីជម្រើសគោលនយោបាយ និង ៣) លើកកម្ពស់ភាពជាដៃគូរវាងគ្នា។

### ២.២. សុន្ទរកថាបើក ដោយលោកស្រី Meloney C. Lindberg

ដើម្បីបន្តការប្តេជ្ញារួមគ្នាចំពោះ SDGs អង្គការមូលនិធិអាស៊ី (TAF) ដើរតួនាទីយ៉ាងសំខាន់ក្នុងការជានាបាននូវវេទិកាពិភាក្សាប្រកបដោយបរិយាបន្ន ផ្អែកលើភស្តុតាង និងការចូលរួម តាមរយៈការចូលរួមពីភាគីពាក់ព័ន្ធចម្រុះស្ថាប័ន រួមមានភ្នាក់ងាររាជរដ្ឋាភិបាល សង្គមស៊ីវិល ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន។ បន្ថែមពីលើកិច្ចសហប្រតិបត្តិការពីមុនជាមួយ AVI ចាប់តាំងពីពេលដែលវិទ្យាស្ថាននេះទើបតែបានបង្កើតឡើងមក អង្គការមូលនិធិអាស៊ី (TAF) នៅតែបន្តក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីពង្រឹងកិច្ចសន្ទនា និងសកម្មភាពរួមគ្នាឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសតាមរយៈ**កម្មវិធីពន្លកចំណេះ II**៖ ទិន្នន័យ និងកិច្ចពិភាក្សាដើម្បីការអភិវឌ្ឍ។ **កិច្ចសន្ទនាស្តីពី៖ យេនឌ័រ-គោលនយោបាយឆ្លើយតបក្នុងវិស័យព្រៃឈើ - ការចូលរួមរបស់ស្ត្រីក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ** ជាវឌ្ឍនភាពដ៏ជាក់ច្បាស់មួយ ដែលត្រូវបានផ្តួចផ្តើមឡើងដោយមានការគាំទ្រពីអង្គការមូលនិធិអាស៊ី (TAF) និងរដ្ឋាភិបាលអូស្ត្រាលី។ គំនិតផ្តួចផ្តើមនេះមានគោលបំណងជាយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ដំណោះស្រាយប្រកបដោយបរិយាបន្ន និងផ្អែកលើភស្តុតាង ស្របគ្នាជាមួយនឹងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកអនាគតដែលកាន់តែមានភាពធន់ សមធម៌ និងប្រកបដោយចីរភាព។

### ២.៣. សន្ទរកថាគន្លឹះដោយ លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគីន

លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគីន បានផ្តល់រៀបរាប់អំពីទិដ្ឋភាពទូទៅនៃកំណើនកសិកម្ម ដែលមានចំនួន ១៦.៥% នៃផលិតផលក្នុងស្រុកសរុប (GDP)។ សហគមន៍ព្រៃឈើចំនួន ៦៥៥ ត្រូវបានទទួលថវិកាគាំទ្រដែលមានទំហំទឹកប្រាក់ចំនួន ៨,៨៣៣ លានរៀល។ ពិសេសជាងនេះទៅទៀត សមាជិកសហគមន៍ចំនួន ១៧២,៣៩៨ នាក់ បានរួមគ្នាសម្របសម្រួលការគ្រប់គ្រង និងការអភិវឌ្ឍធនធានធម្មជាតិព្រៃឈើ និងការដាំដុះថ្មីលើផ្ទៃដីទំហំ ២២,៩០០ ហិកតា។

លោកជំទាវបណ្ឌិតបានលើកឡើងបន្ថែមថា គោលនយោបាយបញ្ជ្រាបយេនឌ័រនិងក្របខណ្ឌយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម (២០២២-២០២៦) រួមទាំងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់វិស័យព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដោះស្រាយបញ្ហាប្រឈមជាបន្តបន្ទាប់នៃចូលរួមតំណាងតិចតួចរបស់ស្ត្រី និងការលំបាករបស់ស្ត្រីក្នុងការទទួលបានឱកាស។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងលើកកម្ពស់ជាលក្ខណៈប្រព័ន្ធដើម្បីបញ្ជ្រាបយេនឌ័រដោយជួយឱ្យស្ត្រីទទួលបានធនធានសមធម៌ ការបណ្តុះបណ្តាល និងជំនាញក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលស្របនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥។ លើសពីនេះ ផែនការយុទ្ធសាស្ត្រយេនឌ័រក្នុងវិស័យព្រៃឈើត្រូវបានបង្កើតឡើង ដើម្បីផ្តល់ចំណេះដឹង និងការអនុវត្តដោយផ្ទាល់បន្ថែមទៀត ដែលអាចជួយទ្រទ្រង់ដល់ព្រៃឈើ។ ភាពគង់វង្សរបស់ព្រៃឈើ គឺភាគច្រើនកើតចេញពីការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការអភិរក្សជីវៈចម្រុះ ដែលផ្តល់នូវការរួមចំណែកយ៉ាងសំខាន់ដល់ការស្រូបយកកាបូន និងការផ្គត់ផ្គង់អាហារ ទឹក និងសេវាកម្មប្រកបដោយផ្លែផ្កា ដែលរួមចំណែកដល់សុខុមាលភាពមនុស្ស និងជំរុញសេដ្ឋកិច្ច។ ការផ្គត់ផ្គង់អាហារ ទឹក និងសេវាកម្មប្រកបដោយផ្លែផ្កានេះ គឺធ្វើឡើងស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអន្តរវិស័យផ្សេងទៀត ជាមួយនិងការនាំមកនូវឱកាសសម្រាប់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់

ដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។ ដំណោះស្រាយប្រកបដោយនវានុវត្តភាព ដែលកើតចេញពីចំណេះដឹងរបស់ស្ត្រី គឺមានប្រយោជន៍សម្រាប់ទាំងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់សមធម៌សង្គម។

ដើម្បីសំយោគវិធីសាស្ត្រឆ្លើយតបនឹងបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយអាកាសធាតុ និងព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាអនុវត្តសកម្មភាពសំខាន់ៗចំនួន ៦ គឺ៖

១. អង្គភាពយេនឌ័រនៅក្នុងស្ថាប័នអន្តរក្រសួងត្រូវបានបង្កើតឡើង ដើម្បីបង្កើតការគិតគូរពិចារណាបញ្ហាយេនឌ័រក្នុងការត្រួតពិនិត្យគំនិតផ្តួចផ្តើមព្រៃឈើ និងអាកាសធាតុ
២. សមភាពយេនឌ័រត្រូវបានបង្ហាញយ៉ាងជាក់ច្បាស់ ដើម្បីលើកកម្ពស់ដល់ស្ត្រី និងសហគមន៍ជនជាតិដើមភាគតិចក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត
៣. សូចនាករបែងចែកភេទត្រូវបានប្រើប្រាស់ ដើម្បីតាមដានការអនុវត្តថវិកាឆ្លើយតបទៅនឹងយេនឌ័រ ដោយធានាបាននូវលទ្ធផលដាច់ដោយឡែករវាងបុរស និងស្ត្រី ដើម្បីកែសម្រួលគោលនយោបាយ
៤. ការកសាងសមត្ថភាពលើបញ្ហារសើបរបស់យេនឌ័រកំពុងត្រូវបានធ្វើឡើង ដើម្បីបង្កើនការយល់ដឹងអំពីបទដ្ឋានវប្បធម៌ដែលកំពុងផ្លាស់ប្តូរ ដោយផ្តោតលើតួនាទីយេនឌ័រក្នុងការគ្រប់គ្រងព្រៃឈើ
៥. ធនធានសមធម៌ (ដូចជា៖ ហិរញ្ញវត្ថុ ការរស់នៅ និងការគាំទ្របច្ចេកទេស) ត្រូវបានបណ្តុះបណ្តាលជូនស្ត្រី ដើម្បីលើកកម្ពស់សេដ្ឋកិច្ចរបស់ពួកគេនៅក្នុងបរិបទបំរែបំរួលអាកាសធាតុ
៦. ក្រសួងជំរុញឱ្យកាត់បន្ថយការរើសអើងផ្នែកច្បាប់ទៅលើស្ត្រី ដោយសម្រួលឱ្យស្ត្រីមានលទ្ធភាពក្នុងការទទួលបានដីធ្លី និងធនធានព្រៃឈើ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះជំហានដែលអាចអនុវត្តទៅបានដោយផ្អែកលើវិធីសាស្ត្ររួមបញ្ចូលយេនឌ័រ៖

១. ក្រសួងនឹងយកចិត្តទុកដាក់លើការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ ដោយធានាថាយន្តការទាំងនេះនឹងត្រូវបានអនុវត្ត
២. កម្មវិធីបណ្តុះបណ្តាល និងជំនាញសំខាន់ៗនឹងត្រូវបានផ្តល់ជូនដល់ស្ត្រី ដើម្បីចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធាន
៣. ការប្រមូលទិន្នន័យស្តីពីតួនាទីយេនឌ័រនឹងធ្វើឱ្យការសម្រេចចិត្តគោលនយោបាយ និងការបែងចែកធនធានក្នុងវិស័យព្រៃឈើកាន់តែមានភាពប្រសើរឡើង
៤. វេទិកាប្រកបដោយបរិយាប័ន្នសម្រាប់ស្ត្រីក្នុងវិស័យកសិកម្ម និងព្រៃឈើ ដែលធ្វើឡើងដោយភាគីពាក់ព័ន្ធជាច្រើន (ដូចជា៖ រដ្ឋាភិបាល សង្គមស៊ីវិល ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន) នឹងត្រូវបានលើកទឹកចិត្តដោយក្រសួង
៥. ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃដែលមានសុពលភាពនឹងត្រូវបានជំរុញឱ្យក្លាយជាមាត្រដ្ឋានដើម្បីដោះស្រាយផលប៉ះពាល់នៃគោលនយោបាយឆ្លើយតបទៅនឹងយេនឌ័រលើលទ្ធផលរយៈពេលវែង។

| សកម្មភាពសំខាន់ៗសម្រាប់វិធីសាស្ត្ររួមបញ្ចូល | ចក្ខុវិស័យឆ្ពោះទៅមុខ |
|---|---|
| ១. ការរៀបចំស្ថាប័នសម្រាប់ការរួមបញ្ចូលយេនឌ័រ | ១. ការពង្រឹងក្របខ័ណ្ឌច្បាប់ |
| ២. ការបញ្ជ្រាបគោលការណ៍យេនឌ័រទៅក្នុងគោលនយោបាយ និងច្បាប់ | ២. ការលើកកម្ពស់ការកសាងសមត្ថភាព |
| ៣. ការរៀបចំថវិកា ការត្រួតពិនិត្យនិងវាយតម្លៃ(M&E) | ៣. ការពង្រឹងការប្រមូលទិន្នន័យ |
| ៤. ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹង | ៤. ការលើកកម្ពស់កិច្ចសហការ |
| ៥. ការទទួលស្គាល់ផ្លូវច្បាប់នូវសិទ្ធិ | ៥. ការត្រួតពិនិត្យ និងវាយតម្លៃ (M&E) |

### ២.៤. ការធ្វើបទបង្ហាញដោយ លោកស្រី ធន រដ្ឋា

លោកស្រី ធន រដ្ឋា បានផ្តល់បទបង្ហាញដោយបានលើកឡើងអំពីតួនាទីរបស់**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦** (២០២៤-២០២៨)។ លោកស្រីបានបញ្ជាក់អំពីទំនាក់ទំនងរវាងគោលនយោបាយដែលផ្តោតលើការផ្លាស់ប្តូរយេនឌ័រ និងការអភិវឌ្ឍជនបទ ដោយបានគូសបញ្ជាក់ពីការរួមបញ្ចូលនៃការគិតគូរពិចារណាយេនឌ័រទៅក្នុងសេចក្តីព្រាងគោលនយោបាយ និងដំណើរការ ព្រមទាំងការពង្រឹងសំឡេង និងលើកកម្ពស់ស្ត្រី។

នៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ (២០២៤-២០២៨) ក្រសួងកិច្ចការនារីមានគោលបំណងពង្រីកគោលនយោបាយ និងកម្មវិធីដែលគាំទ្រតួនាទីរបស់ស្ត្រីនៅក្នុងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ក្រសួងកិច្ចការនារីក៏ព្យាយាមបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងវិស័យអាកាសធាតុ និងបរិស្ថាន ដោយពង្រីកការកសាងសមត្ថភាពទាក់ទងនឹងផែនការយុទ្ធសាស្ត្រក្នុងយេនឌ័រនិងអាកាសធាតុ ដោះស្រាយតម្រូវការជាក់លាក់សម្រាប់ជនងាយរងគ្រោះ ឬស្ត្រីដែលមិនត្រូវបានរាប់បញ្ចូល និងផ្សព្វផ្សាយព័ត៌មានអំពីតួនាទីរបស់ស្ត្រី និងសមភាពយេនឌ័រក្នុងវិស័យអាកាសធាតុ។

លោកស្រីបានគូសបញ្ជាក់អំពីកត្តាជាក់លាក់ចំនួន ៥ ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ រួមមាន៖

១. ការស៊ីសង្វាក់គ្នា និងការសម្របសម្រួល;
២. ការកសាងសមត្ថភាព ការចែករំលែកចំណេះដឹង និងការទំនាក់ទំនង;
៣. តុល្យភាពយេនឌ័រ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី;
៤. ការអនុវត្តគោលនយោបាយឆ្លើយតបយេនឌ័រ និងមធ្យោបាយនៃការអនុវត្ត;
៥. ការត្រួតពិនិត្យ និងការរាយការណ៍។

ក្រសួងកិច្ចការនារីតែងតែលើកទឹកចិត្តដល់ភាគីរួមចំណែកនានាឱ្យធ្វើការសិក្សាស្រាវជ្រាវ និងកិច្ចសន្ទនាអំពីបញ្ហាយេនឌ័រជាច្រើនបន្តបន្ទាប់ និងអនុវត្តវិធីសាស្ត្រផ្លាស់ប្តូរយេនឌ័រ និងយន្តការយេនឌ័រនៅគ្រប់កម្រិតនៃវិស័យសំខាន់ៗ។ ជាពិសេស លោកស្រីមានសេចក្តីសោមនស្សចំពោះកម្មវិធីកិច្ចសន្ទនា SDGs ដែលផ្តួចផ្តើមឡើងដោយ AVI និងមានការគាំទ្រពីស្ថានទូតអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី នេះ ព្រោះគោលនយោបាយឆ្លើយតបនឹងយេនឌ័រ និងបញ្ហាពាក់ព័ន្ធនានា ព្រមទាំងដំណោះស្រាយទាក់ទងនឹងយេនឌ័រទៅលើការប្រែប្រួលអាកាសធាតុត្រូវការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជន។ លើសពីនេះ ក្រសួងកិច្ចការនារីបានគាំទ្រក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធនានាក្នុងការលើកកម្ពស់យេនឌ័រក្នុងការរៀបចំស្ថាប័ន នៅគ្រប់វិស័យ តាមរយៈកម្មវិធីថវិកាឆ្លើយតបទៅនឹងយេនឌ័រ (GRB) និងគំនិតផ្តួចផ្តើមយេនឌ័រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងការតស៊ូមតិនានា។

## ២.៥. ចំណុចសំខាន់ៗនៃកិច្ចពិភាក្សាតុមូល

បន្ទាប់ពីការធ្វើសុន្ទរកថា និងបទបង្ហាញរួចមក កិច្ចពិភាក្សាតុមូលដ៏សំខាន់របស់កម្មវិធីកិច្ចសន្ទនា AVI-SDGs ត្រូវបានធ្វើឡើង ដោយមានការសម្របសម្រួលដោយ**លោក ថុង ម៉េងដាវីដ** អនុប្រធានមជ្ឈមណ្ឌលសិក្សាចិន-អាស៊ាន នៃសាកលវិទ្យាល័យ CamTech ជាមួយវាគ្មិនកិត្តិយសចំនួន ៣ រូប គឺលោកជំទាវបណ្ឌិត យ៉ើ អាស៊ីគីន; លោកស្រី ធន រដ្ឋា; និងលោកស្រី ងិន ណារីរៈ ដែលមានសេចក្តីសង្ខេបសំខាន់ៗដូចខាងក្រោម៖

**សំណួរទីមួយ៖ តើវិធីសាស្រ្តរួមបញ្ចូលត្រូវបានធ្វើឡើងយ៉ាងដូចម្តេចនៅក្នុងគោលនយោបាយជាតិស្តីពីអាកាសធាតុ និងព្រៃឈើក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥, ១០ និង១៣?**

ការពិភាក្សាបានផ្តល់នូវការយល់ដឹងអំពីការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយឆ្លុះបញ្ចាំងពីការបង្កើតក្រុមស្ត្រី និងកុមារ។ ការតភ្ជាប់ប្រកបដោយបរិយាប័ន្នមួយត្រូវបានបង្កើតឡើងរវាងក្រសួងបរិស្ថាន (MoE) ក្រុមបច្ចេកទេសនៃផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការលើសកម្មភាពទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។ ម្យ៉ាងវិញទៀត អន្តរកម្មមួយបានកើតឡើងរវាងគោលនយោបាយ និងការឆ្លើយតបអាកាសធាតុ (ជាពិសេសផែនការយុទ្ធសាស្រ្តនារីរតនៈទី៦) និងតួនាទីស្ថាប័ន (ជាពិសេសក្រសួងកិច្ចការនារី) ដែលមានតួនាទីសំខាន់ក្នុងការផ្តល់កិច្ចពិគ្រោះយោបល់ និងរួមចំណែកដល់ការបញ្ជ្រាបយេនឌ័រ និងការចូលរួមពីក្រសួងពាក់ព័ន្ធដើម្បីអនុវត្តឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ លើសពីនេះ កិច្ចពិភាក្សាបានលើកឡើងអំពីតួនាទីនៃការអប់រំក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងបានបង្ហាញយ៉ាងច្បាស់អំពីចំណេះដឹងរបស់ស្ត្រីលើរុក្ខជាតិឱសថ ការគ្រប់គ្រងហិរញ្ញវត្ថុ កសិកម្មឆ្លាតវៃ ការអប់រំ និងផលិតផលកើតចេញពីអនុផលព្រៃឈើ (NTFPs) ដែលនឹងលើកកម្ពស់ការបង្កើតប្រាក់ចំណូល ហើយអាចសម្រេចបានតាមរយៈកិច្ចសហការរវាងភាគីចូលរួមពាក់ព័ន្ធ។

**សំណួរទីពីរ៖ តើមានរបកគំហើញអ្វីខ្លះដែលអាចទាញចេញពីសហគមន៍ព្រៃឈើក្នុងស្រុក ដែលស្ត្រី ស្ត្រីជនជាតិដើមភាគតិច ឬស្ត្រីដែលមានពិការភាពចូលរួមក្នុងការពង្រឹងសកម្មភាពអាកាសធាតុ?**

វាគ្មិនរបស់យើងបានចង្អុលបង្ហាញឱ្យឃើញថា ការកសាងសមត្ថភាពរបស់ស្ត្រីក្នុងការគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅតែជួបប្រទះនឹងបញ្ហាប្រឈម។ ឧទាហរណ៍ដូចជា ករណីស្ត្រីមួយចំនួនដែលមានតួនាទីនៅក្នុងការសម្រេចចិត្តរបស់សហគមន៍ព្រៃឈើភាគច្រើនអាចអនុវត្តបានល្អ និងអាចប្រើប្រាស់អំណាចរបស់ពួកគេបានត្រឹមត្រូវក្នុងរយៈពេលខ្លីប៉ុណ្ណោះ ព្រោះដោយសារតែឱកាសកសាងសមត្ថភាពមិនមានគ្រប់គ្រាន់។ កិច្ចពិភាក្សារបស់យើងបានបញ្ជាក់យ៉ាងច្បាស់ថា ស្ត្រីពិតជាមានសមត្ថភាពក្នុងការបំពេញតួនាទីជាអ្នកសម្រេចចិត្តទាំងនោះ ប៉ុន្តែពួកគេត្រូវការចាំបាច់នូវការគាំទ្រដ៏ត្រឹមត្រូវ ឬការកសាងសមត្ថភាពសំខាន់ៗ ដែលមានដូចជា៖ កសិកម្មឆ្លាតវៃដែលរួមចំណែកដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) ការប្រមូលអនុផលព្រៃឈើប្រកបដោយចីរភាព និងការអភិរក្សព្រៃឈើជាដើម។ កិច្ចពិភាក្សារបស់យើងនេះក៏បានគូសបញ្ជាក់ពីការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពអាកាសធាតុជាមួយនឹងគោលការណ៍សមធម៌សង្គមដងដែរ ដែលមានដូចជា៖ នៅក្នុងការងារយាមល្បាតព្រៃឈើ ស្ត្រីអាចចូលរួមនៅក្នុងកិច្ចការងារនេះនៅវេនថ្ងៃ ខណៈពេលដែលបុរសយាមល្បាតនៅពេលយប់។

Australian Aid

PONLOK CHOMNES

The Asia Foundation

**សំណួរទីបី៖ តើការកសាងសមត្ថភាពក្នុងទម្រង់បែបណាដែលត្រូវការចាំបាច់ដើម្បីលើកកម្ពស់គោលនយោបាយឆ្លើយតបទៅនឹងយេនឌ័រក្នុងសកម្មភាពអាកាសធាតុ?**

វាគ្មិនរបស់យើងបានពន្យល់ថា គំនិតផ្តួចផ្តើមកសាងសមត្ថភាពត្រូវបានអនុវត្តមិនត្រឹមតែនៅថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅថ្នាក់ក្រោមជាតិ ឬថ្នាក់មូលដ្ឋានផងដែរ។ គំនិតផ្តួចផ្តើមកសាងសមត្ថភាពទាំងនេះនឹងផ្តោតលើការត្រៀមខ្លួនសម្រាប់ហានិភ័យនិងគ្រោះមហន្តរាយ ការបន្សុំខ្លួនទៅនឹងបម្រែបម្រួលអាកាធាតុ និងការកែលម្អជីវភាពរស់នៅក្នុងគោលបំណងបង្កើនជីវភាពរស់នៅ និងឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រី ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីដែលមានពិការភាពជាដើម។ ការកសាងសមត្ថភាពគួរតែរួមបញ្ចូលទាំងគោលគំនិតនៃការប្រែប្រួលអាកាសធាតុ និងការគិតគូរពិចារណាលើបញ្ហាយេនឌ័រ ដើម្បីអនុញ្ញាតឱ្យស្ត្រីអាចចែករំលែកការយល់ដឹងគ្នាទៅវិញទៅមក និងកំណត់តម្រូវការ រួមទាំងដំណោះស្រាយជាក់ស្តែងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ដំណើរការនៃការកសាងសមត្ថភាពនេះគួរតែរួមបញ្ចូលគោលនយោបាយ យន្តការ និងការប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ ដែលក្នុងនោះប្រព័ន្ធស្ថិតិយេនឌ័រជាតិ ស្តីពីយេនឌ័រនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ (ការបន្សុំខ្លួន និងការកាត់ទប់ស្កាត់) ជាវិធានការសម្រាប់ការលើកកម្ពស់ជីវភាព ជាពិសេសតាមរយៈទិន្នផល និងផ្សព្វផ្សាយកសិកម្ម។

*****

# The AVI – SDGs Dialogue

## Gender-Responsive Policies in Forestry—Women's Inclusion in Climate Change

## 18 September 2025

## Summary Report

### I. Introduction and Overview

The AVI-SDGs dialogue on "Gender-Responsive Policies in Forestry – Women's Inclusion in Climate Change" was held on September 18th which is timely important to the current context in response to the needs of gender considerations in climate mitigation efforts, with 57% of female participants of the total participants from 18 institutions. This summary report captures an overview of discuss and dialogue's key messages. The dialogue started with remark speeches, followed by the presentation and round table discussion at the end, from our distinguished speakers and panelist as follows:

1. **Dr. NGUONPHAN Pheakdey**, Vice President of the Asian Vision Institute (AVI);
2. **Ms. Meloney C. Lindberg**, Country Representative of The Asia Foundation (TAF);
3. **Ms. Evangeline Lasen**, Second Secretary of the Australian Embassy in Phnom Penh;
4. **H.E. Dr. YOEU Asikin**, Under-Secretary of State of the Ministry of Agriculture, Forestry and Fisheries (MAFF);
5. **Ms. CHHAN Ratha**, Deputy Director General of the Ministry of Women's Affairs (MoWA);
6. **Ms. NGIN Navirak**, National Coordinator of the Global Environmental Facility Small Grants Programme of the United Nations Development Programme (UNDP).

### II. Key Outcomes and Messages

#### 1. Welcome Remarks by Dr. NGUONPHAN Pheakdey

Since 2019, the Asian Vision Institute (AVI) has contributed to Cambodia's development through research, dialogue, and the promotion of a peaceful, inclusive, adaptive, and sustainable society. Building on this mission, the AVI has produced hundreds of works, including commentaries, policy briefs, perspective books, magazines, interviews, media engagement, and primary-data surveys, etc. These fruitful results are supported by national and international experts; advisors; researchers; fellows and interns. AVI also forcuses on the Sustainable Development Goals (SDGs) which is known for its universal, transformative, inclusive, human-progress-oriented, biodiversity-conserving, and environmentally protective. As women's participation in climate action, especially their roles in managing, decision-making, problem solving, planning and resource mobilizing are increasingly important, this dialogue, which is supported by the Ponlok Chamnes Program of the TAF and the Australian Embassy in Phnom Penh, aims to: 1) bring together stakeholders for discuss, 2) inform policy options, and 3) foster partnerships.

#### 2. Opening Remarks by Ms. Meloney C. Lindberg

In pursuit of the shared commitment to the SDGs, the Asia Foundation (TAF) plays a pivotal role in ensuring that the platform is inclusive, evidence-based, and participatory, engaging diverse stakeholders including government agencies, civil society, researchers, think tanks and the private sector. Building upon the previous collaboration with the Asia Vision Institute (AVI) shortly after the AVI was established as a promising research

institute, the Asia Foundation (TAF) remains unwavering in its efforts to strengthens dialogue and collective action toward sustainable development, particularly through the Ponlok Chomnes II: Data and Dialogue for Development program. As part of the visible progress, the Dialogue on Gender-Responsive Policies in Forestry — Women's Inclusion in Climate Change Mitigation has been initiated with the support of the Asia Foundation (TAF) and the Australia Government. This initiative strategically seeks to foster inclusive, and evidence-based solutions, in parallel with efforts toward a more resilient, equitable, and sustainable future.

3. **Keynote Remarks by H.E. Dr. YOEU Asikin**

H.E. Dr. YOEU Asikin explicitly offered an overview of agricultural growth, amounting for 16.5% of national Gross Domestic Product (GDP). Statistically, 655 forestry communities were supported, amounting for 8,833 million Riels. In particular, 172,398 community members jointly facilitated the management and development of forest natural resources and the new plantation on an area of 22,900 hectares.

She highlighted further that the gender mainstreaming and strategic framework in agriculture (2022-2026) and gender mainstreaming strategic plan for the forestry sector, that address the continued challenges of underrepresentation of women and the constraints they face in accessing opportunities. The MAFF is systematically fostering gender mainstreaming by equipping women with equitable resources, training, and decision-making skill, which is aligning with the SDG 5. In addition, a Gender Strategic Plan in the forestry sector was crafted to gain more knowledge and first-hand practices that sustain forests. Healthy forests, which is mainly stemmed from sustainable forest management and biodiversity conservation, provide a significant contribution to carbon sequestration and fruitfully supply of food, water, and services contributing to the human well-being and economic empowerment. The fruitful supply of food, water and services is in harmonised with cross cutting SDG themes and bring opportunities for gender-responsive mitigation efforts. Innovative solutions which are rooted in women knowledge is beneficial for both mitigating the climate change impacts and fostering social equity.

To synthesize gender-responsive approaches into climate and forestry policies, the MAFF committedly undertake 6 key actions. First, gender units within inter-ministerial bodies were created to establish gender consideration in overseeing forestry and climate initiative. Second, gender equality is explicitly illustrated to empower women and indigenous communities in decision making process. Third, sex-disaggregated indicators are utilized to track the gender-responsive budget implementation, ensuring the segregated outcomes between men and women to adjust policy. Forth, gender sensitivity capacity buildings are being conducted to raise awareness on cultural norms shifting, focusing on gender roles in forest management. Fifth, equitable resources (e.g., finance, alternative livelihood, and technical support) are equipped to women to empower their economic in climate context. Sixth, the ministry urges to reduce legal discrimination against women, facilitating women with access to land and forest resources.

The MAFF reaffirms the unwavering commitment to actionable steps grounded on gender inclusive approaches. First, the ministry will pay attention on implementation and enforcement of existing laws and regulations, ascertaining that these instruments will be applied. Second, training programmes and important skills will be delivered to women to participate actively in resource management. Third, data collection on gender roles will better shape policy decision and resource allocation in forestry. Forth, an inclusive platform for women in agriculture and forestry conducted by multiple stakeholders (e.g., government, civil society, researchers, think tanks, and the private sector) will be encouraged by the ministry. Fifth, valid monitoring and evaluation frameworks will be urged to be a yardstick to tackle the effects of gender-responsive policies on long-term outcomes.

| Key Actions for Inclusive Approaches | Way Forward |
|---|---|
| 1. Institutional Arrangement for Gender Inclusion<br>2. Gender Principles in Policies and Laws<br>3. Budgeting, Monitoring & Evaluation (M&E)<br>4. Capacity Building and Raising Awareness<br>5. Legal Recognition of Rights | 1. Strengthening Legal Framework<br>2. Enhancing Capacity Building<br>3. Strengthening Data Collection<br>4. Fostering Collaboration<br>5. Monitoring and Evaluation (M&E) |

### 4. Presentation by Ms. CHHAN Ratha

Ms. CHHAN Ratha began her presentation by stating the role of Neary Rattanak 6 (2024 – 2028). She significantly reflected the linkage between the gender-transformative approached policy and rural development, underscoring on the integration of gender considerations into draft policies and process and on amplifying women's voices and empowerment.

In Neary Rattanak 6 (2024 – 2028), the MoWA aims to scale up the policy and programme which support women's role in climate change and disaster risk reduction. The MoWA also seeks to reinforce gender mainstreaming in climate and green sectors by broadening capacity building in relative to strategic plan in gender and climate, addressing specific needs for vulnerable or women who are excluded, and disseminating information of women's roles and gender equality in climate sector.

Ms. Ratha notably highlighted five particular areas in gender mainstreaming in climate change adaptation namely (1) Coherence and Coordination; (2) Capacity-Building, Knowledge Sharing, and Communication; (3) Gender Balance, Participation, and Women's Leadership; (4) Gender-Responsive Implementation and Means of Implementation; (5) Monitoring and Reporting. The MoWA is consistently encouraging multi-stakeholders to conduct numerous gender research studies and dialogues, and to apply gender-transformative approaches and gender mechanism in all level of key sectors. Particularly, she appreciated having this SDGs dialogue initiated by the Asian Vision Institute (AVI), with the support of the Australian Embassy and the Asia Foundation, as gender-responsive policies and gender-related issues and solutions in climate change need to be widely disseminated to the public. Additionally, the MoWA supports line ministries and partners in promoting gender institutionalization across their sectors through the Gender-Responsive Budgeting (GRB) Programme and Gender in Media and Advocacy initiatives.

### 5. Highlights of the Roundtable Dialogue

After the remarks and presentation, the significant roundtable dialogue, moderated by Mr. THONG Mengdavid - Deputy Director China-ASEAN Studies Center of CamTech University, took place with 3 panelists H.E. Dr. YOEU Asikin; Ms. CHHAN Ratha; and Ms. Navirak Ngin, with key summary as follows:

The first question: **How are inclusive approaches reflected in national climate and forestry policies in achieving SDG 5, 10, and 13?**

The dialogue offered an insight into gender mainstreaming in national and sub-national level by reflecting the establishment of Women and Children Groups. There is an inclusive linkage between the Ministry of Environment (MoE), technical groups of the Nationally Determined Contribution (NDC), and the MAFF to work on the climate mitigation actions. In addition, there is an inter-play between the policies and climate response, particularly the Neary Rattanak 6, and the institutional roles, particularly the MoWA, in which the institute has a critical role in providing consultation and contributing to gender mainstreaming and engaging line ministries to align with the SDGs. Moreover, the dialogue reflected the role of education in livelihood

alleviation, and vividly exemplified women's knowledge on medicinal plants, financial management, smart agriculture, education, and non-timber forest products (NTFPs) that will promote income generation and can be achieved through collaboration among relevant stakeholders.

The second question: **What findings can be drawn from the local forestry community, where women; indigenous women or women with disabilities participate in strengthening climate actions?**

The panelist pointed out that women's capacity building in effectively supporting progress toward the SDGs still faces challenges. For example, some women in decision-making positions in the forestry community mostly can perform well and properly exercise their power for quite a short period of time due to insufficient capacity building opportunities. The discussion explicitly emphasized that women actually have the ability to perform those roles but they need proper or key capacity building supports, for example: smart agriculture, which contribute to the mitigation of greenhouse gases (GHG); sustainable collection of the NTFPs; and forest conservation. The discussion also underscored the involvement of women in climate actions with the principle of social equity – for example: in forest patrolling work, women can participate in daytime shift, while men patrol at nighttime shift.

The third question: **What form of capacity building are needed to foster gender-responsive policies in climate actions?**

The panelist explained that capacity building initiatives are implemented not only at the national level, but also at sub-national or local levels. These capacity building initiatives would be on risk & disaster preparedness, climate change adaptation, and livelihood improvement with the aims to enhance the livelihood and economic opportunities of women, indigenous women, and women with disabilities. Capacity building should integrate both the concept of climate change, and gender consideration so that they can share a mutual understanding and identify actual needs and solutions in response to the climate change. The capacity building process should include policies, mechanism, and the use of gender analysis tools, where National Gender Statistics on Gender in the context of climate change (adaptation and mitigation) serve as a measure for enhancing livelihoods, particularly through agricultural outputs and extension.

*****